**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តរតនគិរី**

**សាលក្រមរដ្ឋប្បវេណី**
-លេខ ០៣ "ខ"
ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងរដ្ឋប្បវេណីលេខ ២០
ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តរតនគិរី

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទីម្ភៃប្រាំពីរ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ៥ និង ០០ នាទីរសៀល នៅសាលសវនាការទី២ លើសំណុំរឿងរដ្ឋប្បវេណីលេខ ២០ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តរតនគិរី

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តរតនគិរី

រវាងដើមចោទឈ្មោះ [redacted] រស្មី ភេទស្រី អាយុ៤២ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិត [redacted] ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] អត្តលេខ ៥៦២ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីមានការិយាល័យស្ថិតនៅ [redacted] ។

និងចុងចម្លើយឈ្មោះ [redacted] ផល្លី ភេទប្រុស អាយុ៥២ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិត [redacted] ។

អ្នកតំណាងដោយអាណត្តិលោកមេធាវី [redacted] អត្តលេខ ២៨៤៧ T ជាមេធាវី នៃការិយាល័យមេធាវី [redacted] ។

ក-ខ្លឹមសារនៃសាលក្រមដែលភាគីទាមទារឱ្យតុលាការចេញ ៖

១-សុំផ្តាច់នីតិសង្វាសរំលាយសំបុត្រអាពាហ៍ពិពាហ៍លេខ ០៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ។

២-សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស អាយុ១០ឆ្នាំ ។

៣-បង្គាប់ឱ្យចុងចម្លើយបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ក្នុងមួយខែ រហូតដល់កូនពេញវ័យ ។



Scanned with CamScanner

៤-សុំឱ្យតុលាការចេញសាលក្រមប្រគល់ជូនភាគីដើមចោទនូវផ្ទះល្វែង និងដីលំនៅដ្ឋានមួយកន្លែងមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០២-០១២៤ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី (ទ្រព្យឯកជនដើមចោទបានពីអំណោយឪពុកម្តាយ) ។

៥-ប្រគល់ឱ្យស្រីច្បងឈ្មោះ [redacted] ចន្ទសូលីកា នូវដីលំនៅដ្ឋានមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិ១ (យាយទូលចេក) សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ។

៦-សុំបែងចែកជាពីរចំណែកស្មើគ្នា នូវដីលំនៅដ្ឋានមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមខេត្តអូរយ៉ាវ ។

៧-សុំឱ្យតុលាការចេញសាលក្រមប្រគល់ជូនភាគីដើមចោទដីចម្ការមានទំហំ ២៥ហិកតា មានទីតាំងនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ។

៨-សុំបែងចែកជាពីរចំណែកស្មើគ្នា នូវគ្រឿងសង្ហារឹមដែលមានទាំងអស់ ។

៩-សុំបែងចែកបំណុលរួមដែលនៅជាប់ជំពាក់ម្តាយ និងប្អូនប្រុសរបស់ដើមចោទមានចំនួនសរុប ១០.០០០ $ (មួយម៉ឺន) ដុល្លារអាមេរិក ជាពីរចំណែកស្មើគ្នា ។

**ខ-អង្គហេតុ និង ចំណុចវិវាទ**

**ខ.១-ការពន្យល់ត្រួសៗ អំពីដំណើររឿងក្តី ៖**

ដើមចោទឈ្មោះ [redacted] រស្មី និងចុងចម្លើយឈ្មោះ [redacted] ផល្លី បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាកាលពីឆ្នាំ២០០២ ដែលមានទ្រព្យរួម ដីផ្ទះ និង ដីចម្ការ ក្នុងចំណងអាពាហ៍ពិពាហ៍បង្កើតបានកូនចំនួន ៣នាក់ គឺឈ្មោះ [redacted] ចន្ទសូលីកា ភេទស្រី កើតថ្ងៃទី២៣ ខែកុម្ភៈ ឆ្ន២០០៤, ឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ។ ហើយដើមចោទបានប្តឹងសុំឱ្យតុលាការចេញសាលក្រមលែងលះពីឈ្មោះ ទឹម ផល្លី និងសុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ព្រមទាំងទ្រព្យសម្បត្តិរួម ដោយសារអាពាហ៍ពិពាហ៍មិនអាចធ្វើបដិទានឡើងវិញបាន ។

**ខ.២-អង្គហេតុដែលអះអាងដោយភាគីដើមចោទ**

-ដើមចោទឈ្មោះ [redacted] រស្មី បានធ្វើថ្លែងការណ៍ថា ៖ ខ្លួនមិនព្រមផ្សះផ្សាក្នុងការរួមរស់ជាប្តីប្រពន្ធជាមួយចុងចម្លើយដោយសារនៅក្នុងគ្រួសារតែងតែមានទំនាស់ជាញឹកញាប់ និងការរស់នៅមិនចុះសម្រុងនឹងគ្នា ហើយចុងចម្លើយមិនបានបំពេញកាតព្វកិច្ចជាប្តីឡើយ ។ ខ្លួនក្នុងរួមរស់ជាប្តីប្រពន្ធជាមួយចុងចម្លើយបានបង្កើតកូនចំនួន ៣នាក់ ហើយសព្វថ្ងៃនេះកូនឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ និងឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០១៣ នៅជាក្មេងៗ ។ ខ្លួនសុំសិទ្ធិគ្រប់គ្រងម្នាក់ឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ចំណែកឯកូនឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនឯកភាពប្រគល់ទៅឱ្យចុងចម្លើយជាអ្នកគ្រប់គ្រង ។ ខ្លួនមានមុខរបរលក់កូនឈើ ដើមឈើ និងផ្កា មានលទ្ធភាពចិញ្ចឹមកូនចំនួន ២នាក់ ដោយចំណាយប្រចាំថ្ងៃ ទាំងកូនឈឺ ការហូបចុក ក្នុងមួយខែសល់ចំនួន ១០០ ដុល្លារ ហើយទាមទារសោហ៊ុយចិញ្ចឹមកូនក្នុងមួយខែ ៦០០.០០០ (ហុកសិបម៉ឺន) រៀល ។ ខ្លួនទាមទារផ្ទះល្វែង និងដីលំនៅដ្ឋានមួយកន្លែង ស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ជាអំណោយរបស់ឪពុកម្តាយខ្លួនប្រគល់ឱ្យក្រោយអាពាហ៍ពិពាហ៍ ។ ហើយក្រោយមកខ្លួនបានចុះជាកម្មសិទ្ធិដាក់ឈ្មោះជាមួយចុងចម្លើយ



Scanned with CamScanner

មូលហេតុនៃការទាមទារដីនេះវិញ គឺខ្លួនចង់ប្រគល់ដីនេះជូនឪពុកម្ដាយខ្លួនវិញ ។ ចំណែកឯដីលំនៅដ្ឋានមួយកន្លែង ស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ឱ្យទៅកូនស្រីឈ្មោះ [redacted] ចន្ទសូលីកា ព្រោះកូនឈ្មោះ [redacted] ចន្ទសូលីកា ភេទស្រី អាយុ១៩ឆ្នាំ ជាកូនច្បងមិនទាន់បានទទួលមកតពីពួកខ្លួន ។ ហើយដីលំនៅដ្ឋានចំនួន ២ប្លង់ មានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី និងដីចម្ការនេះទំហំ២៥ ហិកតា ស្ថិតនៅភូមិទុស ឃុំតាអង ស្រុកកូនមុំ ខេត្តរតនគិរី ចែកជាពីរស្មើគ្នា ដោយសារខ្លួន និងចុងចម្លើយទិញរយៈពេល ១០ឆ្នាំមកហើយ ចំណែកឯផលដំណាំចុងចម្លើយជាអ្នកប្រមូលផលយកខ្លួនឯង ដោយខ្លួនមិនដែលទទួលបានផលពីចម្ការស្វាយចន្ទីម្ដងទេ ហើយចម្ការនេះទិញពេលការរៀបអាពាហ៍ពិពាហ៍ក្នុងឆ្នាំ ២០០២ ពីជនជាតិ ។

-លោកមេធាវី [redacted] បានធ្វើថ្លែងការណ៍ថា ៖ សំណុំរឿងត្រូវបានលោកចៅក្រមរៀបចំណុចគ្មានវិវាទកូនក្ដីខ្លួនបានឯកភាព ប៉ុន្តែចំណុចវិវាទសុំទាមទារដូចនៅក្នុងពាក្យបណ្ដឹងរបស់កូនក្ដីខ្លួន ។ ចំពោះការទាមទារសោហ៊ុយចាំបាច់ចិញ្ចឹមកូនចំនួន ៦០០.០០០ (ហុកសិបម៉ឺន) រៀល ក្នុងមួយខែ ដោយសារចុងចម្លើយមានមុខរបរជាគ្រូបង្រៀនមានចំណូលថេរ និងមិនមែនបន្ទុកធ្ងន់ធ្ងរសម្រាប់ចុងចម្លើយនោះទេ ។ ចំណែកឯផ្ទះល្វែង និងដីលំនៅដ្ឋានមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២៣ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី គឺកូនក្ដីខ្លួនទទួលបានពីឪពុកម្ដាយគាត់ធ្វើមកតឱ្យកូនក្ដីខ្លួនជាទ្រព្យដោយឡែក សុំឱ្យតុលាការប្រគល់មកកូនក្ដីខ្លួនវិញ ។ ហើយដីលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ដែលមានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ទៅឱ្យកូនស្រីឈ្មោះ [redacted] ចន្ទសូលីកា ជាកូនច្បងទុកជាមតកសម្រាប់គាត់ ។ ជាចុងក្រោយដីមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី និងដីចម្ការទំហំ ២៥ ហិកតា សុំកែតម្រូវទីតាំងតាមលិខិតបញ្ជាក់របស់អាជ្ញាធរ មានស្ថិតនៅភូមិទុស ឃុំតាអង ស្រុកកូនមុំ ខេត្តរតនគិរី ជាពីរចំណែកស្មើគ្នា ដោយផ្អែកតាមការកាន់កាប់ជាក់ស្ដែងរបស់កូនក្ដីខ្លួន និងចុងចម្លើយគ្រប់គ្រងសព្វថ្ងៃនេះ ។

**ខ.៣-អង្គហេតុដែលអះអាងដោយភាគីចុងចម្លើយ**

-ចុងចម្លើយឈ្មោះ [redacted] ផល្លា បានធ្វើសេចក្ដីថ្លែងការណ៍ថា ៖ ខ្លួនឯកភាពក្នុងការលែងលះជាមួយដើមចោទ ដោយសារគាត់បានចុះចេញពីផ្ទះរយៈពេល ១ឆ្នាំ ២ខែហើយ និងបានប្ដឹងខ្លួនរឿងក្ដីផ្សេងទៀត ទើបធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាក្នុងរស់រួមជាប្ដីប្រពន្ធទៀតឡើយ ។ ខ្លួនឯកភាព និងប្រគល់សិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វិរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ទៅឱ្យដើមចោទតាមការទាមទារ ហើយកូនឈ្មោះ ទីម កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនសុំសិទ្ធិគ្រប់គ្រង់ ហើយបច្ចុប្បន្នគាត់កំពុងរស់នៅជាមួយខ្លួន ។ ខ្លួនមានលទ្ធភាពចិញ្ចឹមកូនម្នាក់បានដោយខ្លួនឯង ព្រោះខ្លួនមានវិជ្ជាជីវៈជាគ្រូបង្រៀនភាសាអង់គ្លេស ភាសាថៃ និងធ្វើតុខ្ទបានចំណូលចំនួន ៧០០ ដុល្លារក្នុងមួយខែ ក្រោយពេលចំណាយប្រចាំថ្ងៃរួចមក ក្នុងមួយខែសល់ ២០០ ទៅ ៣០០ ដុល្លារ ហើយខ្លួនមិនឯកភាពក្នុងការជួយបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនក្នុងមួយខែចំនួន ៦០០.០០០ (ហុកសិបម៉ឺនរៀល) ទៅឱ្យដើមចោទទេ ព្រោះដើមចោទមានមុខរបរលក់កូនឈើ និងគ្រឿងសង្ហារឹមហើយ ។ ខ្លួនមិនឯកភាពប្រគល់ផ្ទះល្វែង និងដីលំនៅដ្ឋានមួយកន្លែង ស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ទៅឱ្យដើមចោទទេ ព្រោះផ្ទះល្វែង និងដីលំនៅដ្ឋាននេះ ជាអំណោយរបស់ឪពុកម្ដាយក្មេកខ្លួន បាន



Scanned with CamScanner

ប្រគល់ឱ្យខ្លួន និងប្រពន្ធក្រោយពេលរៀបអាពាហ៍ពិពាហ៍រយៈពេល ៣ឆ្នាំ ព្រោះផ្ទះល្វែង និងដីលំនៅដ្ឋានជាទ្រព្យសម្បត្តិរួម ។ ខ្លួនមិនឯកភាពប្រគល់ដីលំនៅដ្ឋានមួយកន្លែង ស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ឱ្យទៅកូនស្រីឈ្មោះ [redacted] ចន្ទសូលីកា នោះទេ ដោយដីនេះជាទ្រព្យសម្បត្តិរួមរបស់ខ្លួន និងដើមចោទ ដូច្នេះសុំឱ្យតុលាការធ្វើការបែងចែកតាមច្បាប់ ។ ខ្លួនសុំបដិសេធដីមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ហើយខ្លួនពុំមានឯកសារដើម ព្រោះខ្លួនមិនបានរក្សាទុកឯកសារទេ សុំមិនទទួលស្គាល់ឡើយ និងដីចម្ការទំហំ ២៥ ហិកតា ដែលដើមចោទអះអាង គឺដីរបស់បងប្អូនខ្លួនជួយមើលថែ ពុំមែនជាទ្រព្យសម្បត្តិរួមរបស់ខ្លួន និងដើមចោទទេ ហើយក៏ពុំមានឯកសារបញ្ជាក់ ខ្លួនសុំបដិសេធមិនទទួលស្គាល់ ។

-លោកមេធាវី [redacted] បានធ្វើថ្លែងការណ៍ថា ៖ ពាក់ព័ន្ធនឹងចំណុចគ្មានវិវាទកូនក្តីខ្លួនបានឯកភាពហើយ ចំណែកឯចំណុចវិវាទទាំង ៥ចំណុច កូនក្តីខ្លួនសុំធ្វើការបដិសេធចោលទាំងអស់ ។ ចំពោះសោហ៊ុយចិញ្ចឹមកូនចំនួន ៦០០.០០០ (ហុកសិបម៉ឺន) រៀល ក្នុងមួយខែ ដែលដើមចោទបានទាមទារនោះ គឺកូនក្តីខ្លួនមានបន្ទុកត្រូវចិញ្ចឹមកូនម្នាក់ឈ្មោះ [redacted] កុលបុត្រ ភេទប្រុស អាយុ ១៤ឆ្នាំ ។ រីឯផ្ទះល្វែង និងដីលំនៅដ្ឋានដែលមានវិញ្ញាបនបត្រលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ជាទ្រព្យរួមប្តីប្រពន្ធរបស់កូនក្តីខ្លួន ស្នើសុំឱ្យតុលាការជាពីរចំណែកស្មើគ្នា ។ ហើយដីលំនៅដ្ឋានមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ ដែលមានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ទៅឱ្យកូនស្រីឈ្មោះ [redacted] ចន្ទសូលីកា ជាការទាមទារមិនត្រឹមត្រូវនោះទេ ព្រោះដីនេះជាទ្រព្យរួមរបស់កូនក្តីខ្លួន ដូច្នេះស្នើសុំឱ្យតុលាការបែងចែកជាពីរចំណែកស្មើគ្នា ។ កូនក្តីខ្លួនសុំបដិសេធដីមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី និងសុំបដិសេធដីចម្ការទំហំ ២៥ ហិកតា មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ពុំមែនជាទ្រព្យរបស់កូនក្តីខ្លួនទេ ដោយគ្មានលិខិតកាន់កាប់ ឬព្រំប្រទល់ច្បាស់លាស់ទេ ហេតុដូច្នេះ កូនក្តីខ្លួនសុំធ្វើការបដិសេធចោលទាំងស្រុងរាល់ការទាមទារដើមចោទ ។

**ខ.២-អង្គហេតុដែលគ្មានវិវាទ**

១-ដើមចោទ និងចុងចម្លើយបានឯកភាពគ្នាការលែងលះតាមឆន្ទៈរបស់ខ្លួន ផ្អែកតាមសំបុត្រអាពាហ៍ពិពាហ៍លេខ ០៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ។

២-ដើមចោទ និងចុងចម្លើយព្រមព្រៀងប្រគល់សិទ្ធិគ្រប់គ្រងកូនប្រុសឈ្មោះ [redacted] កុលបុត្រា ទៅឱ្យចុងចម្លើយ ដែលមានសំបុត្រកំណើតលេខ ៥៧ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៩ និងកូនប្រុសឈ្មោះ [redacted] វិរៈរក្សា ទៅឱ្យដើមចោទ ដែលមានសំបុត្រកំណើតលេខ ២៥ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។

៣-ដើមចោទ និងចុងចម្លើយបានព្រមព្រៀងបែងចែកលើគ្រឿងសង្ហារឹម និងបំណុលរួមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារសហរដ្ឋអាមេរិក ក្រៅប្រព័ន្ធតុលាការ ។

**ខ.៣-ចំណុចវិវាទ**

១-តើស្ថានភាពសេដ្ឋកិច្ចរបស់ចុងចម្លើយមានលទ្ធភាពបង់សោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ក្នុងមួយខែរហូតដល់កូនពេញវ័យ ដូចការទាមទាររបស់ដើមចោទដែរ ឬទេ ?



Scanned with CamScanner

២-តើផ្ទះល្វែង និងដីលំនៅដ្ឋានដែលមានវិញ្ញាបនបត្រលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ជាទ្រព្យរួម ឬទ្រព្យដោយឡែក ?

៣-តើការប្រគល់សិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ទៅឱ្យកូនស្រីឈ្មោះ[redacted]ចន្ទសូលីកា ត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

៤-តើការបែងចែកនូវដីលំនៅដ្ឋាន ដែលមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងបួង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ជាពីរចំណែកស្មើគ្នាត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

៥-តើការទាមទារដីចម្ការទំហំ ២៥ ហិកតា មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ជាទ្រព្យសម្បត្តិរួមដែរ ឬទេ ?

**គ-ការពិនិត្យភស្តុតាង**

**គ.១-ភស្តុតាងដែលដាក់ដោយភាគីដើមចោទ ៖**

- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦
- សៀវភៅគ្រួសារលេខ ២៣៧៥៤ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០២
- សំបុត្របញ្ជាក់កំណើតលេខ ៥៧ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩
- សំបុត្របញ្ជាក់កំណើតលេខ ២៥ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣
- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ៦០២០២០២-០១២៤ ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៧
- លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ៥០៥/២០១១ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១១
- លិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៩
- លិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥
- លិខិតបញ្ជាក់អចលនវត្ថុលេខ ៦០៥/២៣ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២៣

**គ.២-ភស្តុតាងដែលដាក់ដោយចុងចម្លើយ ៖** (គ្មាន) ។

## សំអាងហេតុ

តាមការសាកសួរសាមីភាគី និងពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖ ពាក្យបណ្តឹង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ របស់ឈ្មោះ គីម រស្មី ជាភាគីដើមចោទមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ហេតុដូច្នេះ សាលាដំបូងខេត្តរតនគិរី មានសមត្ថកិច្ច ដើម្បីវិនិច្ឆ័យស្របច្បាប់នូវពាក្យបណ្តឹង ហើយចេញសាលក្រមបានតាមមាត្រា ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ការវិនិច្ឆ័យចំពោះចំណុចគ្មានវិវាទ ៖**

**ក.ការវិនិច្ឆ័យចំពោះចំណុចគ្មានវិវាទទី១ ៖**

១-ដើមចោទបានប្តឹងសុំទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារបង្គាប់ឱ្យដើមចោទលែងលះពីចុងចម្លើយឈ្មោះ [redacted] ផល្លី មានអាសយដ្ឋាននៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។



Scanned with CamScanner

២-តាមរយៈការអះអាងរបស់ដើមចោទ និងចុងចម្លើយបានទទួលស្គាល់នូវអង្គហេតុថា ពួកខ្លួនពិតជាបានរស់នៅមិនចុះសម្រុងនឹងគ្នា ព្រមទាំងរស់នៅបែកបាក់ជាបន្តបន្ទាប់ អស់រយៈពេលយូរឆ្នាំមកហើយ ។ ដើមចោទបានអះអាងទៀតថា មួយរយៈពេលចុងក្រោយនេះ ប្តីប្រពន្ធពួកខ្លួនតែងតែមានទំនាស់នឹងគ្នា ជាញឹកញាប់ដែលទំនាស់នេះនឹងមិនអាចធ្វើការផ្សះផ្សា ដែលធ្វើឱ្យប្តីប្រពន្ធពួកខ្លួនអស់មនោសញ្ចេតនា និងមិនអាចបន្តរួមរស់ជាប្តីប្រពន្ធជាមួយគ្នាបានតទៅទៀតឡើយ ។

៣-សេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលស្នើសុំលែងលះពីចុងចម្លើយ ត្រូវបានចុងចម្លើយបានធ្វើការទទួលស្គាល់ការទាមទារខាងលើនេះផងដែរ ។ ទន្ទឹមនឹងនេះ ភាគីចុងចម្លើយបានបន្ថែមទៀតថា ខ្លួនទទួលស្គាល់ថាពួកខ្លួនពិតជារស់នៅមិនចុះសម្រុងនឹងគ្នាពិតមែន ។

៤-ផ្អែកតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី បានចែងថា "ប្តីប្រពន្ធ អាចដាក់ពាក្យបណ្តឹងលែងលះគ្នាបាន តែក្នុងករណីដែលកំណត់ខាងក្រោម៖ (ចំណុច ង) ករណីផ្សេងទៀតដែលទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបដិទានវិញ បានឡើយ" ។

៥-តាមរយៈសេចក្តីថ្លែងការណ៍ និងការពិនិត្យភស្តុតាងនានីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា ការរស់នៅមិនចុះសម្រុងនឹងគ្នា និងការរស់នៅបែកបាក់ជាបន្តបន្ទាប់របស់ដើមចោទ និងចុងចម្លើយ ពោល គឺធ្វើឱ្យចំណងនៃអាពាហ៍ពិពាហ៍របស់គូភាគីមិនអាចធ្វើបដិទានឡើងវិញបានឡើយ ។

៦-ផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងដើមចោទឈ្មោះ [redacted] វស្មី និងចុងចម្លើយឈ្មោះ [redacted] ផល្លី ដែលបានបង្កើតទំនាក់ទំនងគតិយុត្ត តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦ នៅក្រុងបានលុង ខេត្តរតនគិរី នៅក្រុងបានលុង ខេត្តរតនគិរី ។

៧-ភាគីដើមចោទឈ្មោះ [redacted] វស្មី និងចុងចម្លើយឈ្មោះ [redacted] ផល្លី ដែលបានបង្កើតទំនាក់ទំនងគតិយុត្តិ តាមសំបុត្រអាពាហ៍ពិពាហ៍លេខ ៤ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ ៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦ នៅក្រុងបានលុង ខេត្តរតនគិរី ដែលមានន័យថា គូភាគីទាំងពីរបានបំពេញលក្ខខណ្ឌគតិយុត្តិជាប្តីប្រពន្ធស្របច្បាប់ ។

៨-តុលាការបានធ្វើការវិនិច្ឆ័យថា ការដែលដើមចោទរស់នៅមិនចុះសម្រុងនឹងគ្នាជាមួយនឹងចុងចម្លើយ ហើយបានបែកលំនៅឋានគ្នា គឺជាហេតុធ្វើឱ្យគូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាតទៅទៀត ហើយគ្មានសង្ឃឹមថានឹងធ្វើបដិទានឡើងវិញបាន មានមូលហេតុត្រឹមត្រូវស្របតាមបញ្ញត្តិមាត្រា ៩៧៨ កថាខណ្ឌទី១ ចំណុច ង នៃក្រមរដ្ឋប្បវេណី ។

**ខ.ការវិនិច្ឆ័យចំពោះចំណុចគ្មានវិវាទទី២ ៖**

១-ដើមចោទបានប្តឹងទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារសុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ចំណែកឯកូនឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ខ្លួនឯកភាពប្រគល់ទៅឱ្យចុងចម្លើយជាអ្នកគ្រប់គ្រង ។

២-ផ្អែកតាមសំបុត្រកំណើតលេខ២៥ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលមានឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ និងសំបុត្រកំណើតលេខ ៥៧ ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០០៩ ដែលមានឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ នៅ[redacted] បញ្ជាក់ថា អនីតិជនខាងលើនេះ ពិតជាកូនបង្កើតរបស់ដើមចោទ និងចុងចម្លើយ ពិតប្រាកដមែន ។



Scanned with CamScanner

៣-ភាគីដើមចោទ និងចុងចម្លើយបានពិភាក្សាឯកភាពគ្នាលើការកំណត់ណាម្នាក់ ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] វិរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ កំណត់យកដើមចោទមានសិទ្ធិគ្រប់គ្រង ចំណែកឯកូនឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ កំណត់យកចុងចម្លើយមានសិទ្ធិគ្រប់គ្រង ។ តាមបញ្ញត្តិមាត្រា ១០៣៧ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី បានចែងថា "បើឪពុកម្តាយលែងលះ ត្រូវកំណើតយកឪពុក ឬម្តាយជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្តាយ" ។ ដោយផ្អែកលើអនីតិជនឈ្មោះ [redacted] វិរៈរក្សា និងឈ្មោះ [redacted] កុលបុត្រា បានរស់នៅជាមួយដើមចោទ និងចុងចម្លើយតាំងពីមានកំណើតរហូតដល់បច្ចុប្បន្ន ទទួលបានការមើលថែ និងគ្រប់គ្រងដោយគ្មានកំហុសណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅ និងការសិក្សារបស់អនីតិជនឡើយ ។

៤-ដូច្នេះ គប្បីតុលាការសម្រេចកំណត់យកដើមចោទជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] វិរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ និងកំណត់យកចុងចម្លើយជាអ្នកមានអំណាចមេបាលើកូនឈ្មោះ ឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ តាមការពិភាក្សាគ្នាបាន ។

**គ.ការវិនិច្ឆ័យចំពោះចំណុចគ្មានវិវាទទី២ ៖**

១-ដើមចោទបានប្តឹងទាមទារបែងចែកលើគ្រឿងសង្ហារិម និងបំណុលរួមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ជាពីរចំណែកជាពីរស្មើគ្នា ។

២-ចំពោះគ្រឿងសង្ហារិមដើមចោទ និងចុងចម្លើយ បានព្រមព្រៀងឯកភាពគ្នា ពុំការទាមទារទៀតឡើយ ព្រោះគ្រឿងសង្ហារិមទាំងអស់នោះ ដើមចោទបានអះអាងថា បានលក់អស់យូរហើយ ។

៣-បំណុលរួមចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើមចោទបានអះអាងថា ជាបំណុលជំពាក់ឪពុកម្តាយ ហើយបានដើមចោទលះបង់ការទាមទារនេះ ។ម្យ៉ាងទៀតចុងចម្លើយបានព្រមព្រៀងឯកភាពនឹងអះអាងរបស់ដើមចោទដែរ ។

៤-ហេតុដូច្នេះ គប្បីតុលាការសម្រេចមិនលើកយកមកធ្វើការវិនិច្ឆ័យលើការទាមទាររបស់ដើមចោទនៅត្រង់ចំណុចទី ៨ និងទី ៩ នៃពាក្យបណ្តឹងនោះទេ ។

**ការវិនិច្ឆ័យចំពោះការទាមទារចំណុចវិវាទ ៖**

**ក.ការវិនិច្ឆ័យចំពោះការទាមទារទី១ ៖**

១-ដើមចោទបានប្តឹងទាមទារសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូនចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ក្នុងមួយខែ រហូតដល់កូនពេលវ័យ ។

២-ផ្អែកតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី បានចែងថា "បើការពិភាក្សាខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនតាមការទាមទាររបស់ឪពុក ឬ ម្តាយ" ។

៣-តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ ចំពោះសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមមើលថែរក្សាកូនចំនួន ៦០០.០០០ (ប្រាំមួយសែន) រៀល ក្នុងមួយខែ គូភាគីមានវិវាទនឹងគ្នា ។ តុលាការពិនិត្យឃើញថា ដើមចោទមានមុខរបរជាច្បាស់លាស់ ក្រោយពីការចំណាយប្រចាំថ្ងៃ ក្នុងមួយខែសល់ចំនួន ១០០ (មួយរយ) ដុល្លារអាមេរិក ចំណែកឯចុងចម្លើយក៏មានមុខរបរច្បាស់លាស់ ក្រោយពីការចំណាយប្រចាំថ្ងៃ ក្នុងមួយខែសល់ចំនួន ២០០ (ពីររយ) ដុល្លារអាមេរិក ទៅ ៣០០ (បីរយ)

ដុល្លារអាមេរិក ។ ហើយដើមចោទ និងចុងចម្លើយទទួលបន្ទុកគ្រប់គ្រងចិញ្ចឹមបីបាច់ថែរក្សាកូនម្នាក់មួយ ហេតុដូច្នេះ គប្បីតុលាការមិនសម្រេចអំពីកាតព្វកិច្ចបង់សោហ៊ុយថាំបាច់ យោងតាមបញ្ញត្តិមាត្រា ១០៤០ កថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី ។

**ខ.ការវិនិច្ឆ័យចំពោះការទាមទារ ៖**

១-ដើមចោទបានប្តឹងទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារប្រគល់ជូនភាគីដើមចោទ នូវផ្ទះល្វែង និងដីលំនៅដ្ឋានដែលមានវិញ្ញាបនបត្រលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

២-ភាគីដើមចោទបានថ្លែងការណ៍ថា ផ្ទះល្វែង និងដីលំនៅដ្ឋានដែលមានវិញ្ញាបនបត្រលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ មានទីតាំងស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ជាទ្រព្យឪពុកម្តាយប្រគល់ឱ្យជាអំណោយក្នុងអំឡុងចំណងអាពាហ៍ពិពាហ៍ ។ ម្យ៉ាងទៀតចុងចម្លើយបានក៏អះអាងថា ជាទ្រព្យសម្បត្តិរួមដែលឪពុកម្តាយក្មេកប្រគល់ឱ្យក្នុងចំណងអាពាហ៍ពិពាហ៍ និងបានចុះបញ្ជីកម្មសិទ្ធិរួមគ្នា ពិតប្រាកដមែន ។

៣-ផ្អែកតាមវិញ្ញាបនបត្រលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ចេញមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តរតនគិរី បានបញ្ជាក់ថា ពិតជាកម្មសិទ្ធិស្របច្បាប់របស់ដើមចោទ និងចុងចម្លើយ ពិតប្រាកដមែន ។

៤-ដូច្នេះតាមបញ្ញត្តិមាត្រា ៩៧៣ នៃក្រមរដ្ឋប្បវេណី បានចែងថា ទ្រព្យសម្បត្តិទាំងឡាយដែលប្តីប្រពន្ធទាំងសងខាង ឬតែម្ខាងទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិដែលកំណត់ក្នុងចំណុច ខ និងចំណុច គ នៃមាត្រា ៩៧២ (ទ្រព្យសម្បត្តិដោយឡែក) ខាងលើនេះ ។ ហើយគូភាគីបានដាក់ភស្តុតាង ដើម្បីបញ្ជាក់អំពីអត្ថភាពនៃសិទ្ធិ (ទ្រព្យសម្បត្តិរួម) នៅចំពោះមុខតុលាការ ដើម្បីជាមូលដ្ឋានគតិយុត្ត ក្នុងការសម្រេចវិនិច្ឆ័យបែងចែកទ្រព្យសម្បត្តិរួម ។

**គ.ការវិនិច្ឆ័យចំពោះការទាមទារ ៖**

**១-ដើមចោទបានប្តឹងទាមទារឱ្យតុលាការចេញសាលក្រម ដែលខ្លឹមសារសុំបែងចែកទ្រព្យសម្បត្តរួមដែលមាន ៖**

១.១-ប្រគល់សិទ្ធិកាន់កាប់ដីលំនៅដ្ឋាន ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ទៅឱ្យកូនស្រីឈ្មោះ ទឹម ចន្ទសូលីកា ។

១.២-បែងចែកនូវដីលំនៅដ្ឋាន ដែលមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី ជាពីរចំណែកស្មើគ្នា ។

១.៣-បែងចែកដីចម្ការទំហំ ២៥ ហិកតា មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ជាពីរចំណែកស្មើគ្នា ។

២-ភាគីដើមចោទបានថ្លែងការណ៍ថា ដីលំនៅដ្ឋាន ដែលមានលិខិតផ្ទេរសិទ្ធិកាន់កាប់លេខ ១៣៥/០៩ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី ទៅឱ្យកូនស្រីឈ្មោះ ទឹម ចន្ទសូលីកា និងដីលំនៅដ្ឋាន ដែលមានលិខិតបញ្ជាក់លេខ ១៣៣/០៥ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៥ មានទីតាំងស្ថិតនៅក្នុងប្លង់សាងសង់ផ្សារទីរួមស្រុកអូរយ៉ាដាវ ភូមិអ៊ុន ឃុំលំជ័រ ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី និងដីចម្ការទំហំ ២៥ ហិកតា មានទីតាំងស្ថិតនៅភូមិ១ សង្កាត់កាចាញ ក្រុងបានលុង ខេត្តរតនគិរី មានលិខិតបញ្ជាក់អចលនវត្ថុលេខ ៦០៥/២៣ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៣ ជាពីរចំណែកស្មើគ្នា ។ ម្យ៉ាងទៀត ចុងចម្លើយក៏បានបដិសេធមិនទទួលស្គាល់ការទាមទាររបស់ដើមចោទនោះ យល់ឃើញថា



Scanned with CamScanner

គូភាគីពុំមានភស្តុតាងណាមួយ ដើម្បីបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិ (ទ្រព្យសម្បត្តិរួម) រវាងដើមចោទ និងចុងចម្លើយនោះទេ ដូច្នេះពុំមានមូលដ្ឋានដ្ឋានគតិយុត្ត ក្នុងការសម្រេចអំពីការទាមទារខាងលើនេះឡើយ ។

គ.ប្រាក់ប្រដាប់ក្តី ៖

-ផ្អែកតាមការវិនិច្ឆ័យចំពោះការទាមទារខាងលើនេះ គប្បីឱ្យដើមចោទ និងចុងចម្លើយទទួលបន្ទុកពាក់កណ្តាលម្នាក់លើប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-ដើមចោទឈ្មោះ [redacted] រស្មី លែងលះ ចុងចម្លើយឈ្មោះ [redacted] ផល្លី ។

២-កំណត់ថា ដើមចោទឈ្មោះ [redacted] រស្មី ជាអ្នកមានអំណាចមេបាចំពោះកូនឈ្មោះ [redacted] វីរៈរក្សា ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៣ ។

៣-កំណត់ថា ចុងចម្លើយឈ្មោះ [redacted] ផល្លី ជាអ្នកមានអំណាចមេបាចំពោះកូនឈ្មោះ [redacted] កុលបុត្រា ភេទប្រុស កើតថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ។

៤-បែងចែកទ្រព្យសម្បត្តិរួមទូវផ្ទះល្វែង និងដីលំនៅដ្ឋាន ស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ដែលមានក្បាលដីលេខ ១២៤ ទំហំ ៩៥៧ ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៦០២០២០២-០១២៤ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ ចេញដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តរតនគិរី ឱ្យដើមចោទ និងចុងចម្លើយ ចាត់ចែងជា ២ (ពីរ) ចំណែកស្មើគ្នា នៃតម្លៃអចលនវត្ថុ ។

៥-ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] រស្មី ត្រង់ចំណុចទី៣ ,ទី៥ ទី៦, ទី៧ ,ទី៨, និងចំណុចទី៩ នៃពាក្យបណ្តឹង ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ។

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ និងចុងចម្លើយ ។

សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាអសាធារណៈ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៣ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ចាត់ទុកចំពោះមុខដើមចោទ និងចុងចម្លើយ ។

ទុកសិទ្ធិឱ្យធ្វើបណ្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ តាមបញ្ញត្តិមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា: [redacted]

---

បានថតចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរតនគិរី ថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ និង ឯកភាព

**ចៅក្រមជំនុំជម្រះ**

[redacted]



Scanned with CamScanner